ទិដ្ឋភាពទូទៅនៃសំណួរ និងការពន្យល់

សមាគមដើម្បីការការអភិវឌ្ឍ និងការគាំទ្រវិស័យកៃច្នៃនៃកម្ពុជា(សមាគមស៊ីកាដា)

**ការប្រមូលទិន្នន័យ**

**សម្រាប់ស្ថាប័ន/អង្គភាព**

ធ្វើបច្ចុប្បន្នភាពចុងក្រោយ៖ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២

ដើម្បីឆ្លើយកម្រងសំណួរ សូមចុចទីនេះ

# Question Overview & Explanations

Creative Industries of Cambodia Association for Development and Advocacy (CICADA)

**Data Collection**

**– FOR ORGANISATIONS ONLY –**

Last updated: 28 September 2022

→ Link to the Survey

## កំណត់ចំណាំ

- សមាគមស៊ីកាដា មានផែនការប្រមូលទិន្នន័យពីបុគ្គល និងអង្គភាពដែលធ្វើការក្នុងវិស័យវប្បធម៌ និងច្នៃប្រតិដ្ឋក្នុងប្រទេសកម្ពុជារៀងរាល់ប្រាំមួយខែម្តង ដើម្បីបង្កើតសំណុំទិន្នន័យដ៏រឹងមាំ ដែលនឹងជួយវិស័យនេះឱ្យយល់កាន់តែច្បាស់អំពីនិន្នាការ និងគៀងគរការគាំទ្រសម្រាប់ការអភិវឌ្ឍន៍ និងធ្វើការសម្រេចចិត្ត លើការអភិវឌ្ឍន៍ដែលពាក់ព័ន្ធនានា។
- សូមឆ្លើយតែព័ត៏មានសម្រាប់រយៈ**ពេល ៦ខែកន្លងមក (ខែមករា ដល់មិថុនា ឆ្នាំ ២០២២)។**
- មានទម្រង់ស្ទង់មតិ និងទិដ្ឋភាពទូទៅពីរទម្រង់ផ្សេងគ្នាគឺ៖ សម្រាប់ បុគ្គល និងស្ថាប័ន/អង្គភាព

## Preliminary Notes

- CICADA plans to collect data from individuals and organisations working in the cultural and creative industries in Cambodia every six months to build a strong data set that will help the sector to better understand trends and advocate for improvements, and make relevant development decisions.

- Please report only **information for 1st half of the year [January – June 2022]**
- There are **different survey forms** and question overviews such as this for individuals and organisations.

## ការប្រមូលទិន្នន័យ

សំណួរ៖ តើអ្នកយល់ព្រមចំពោះការប្រមូល ការផ្ទុក ដំណើរការ និងការចែករំលែកជាសាធារណៈនៃទិន្នន័យដែលអ្នកនឹងផ្តល់ក្នុងទម្រង់នេះដែរឬទេ?

- គ្រប់ទិន្នន័យដែលប្រមូលបាន នឹងមិនត្រូវបាន**បញ្ចេញឈ្មោះ។** ដូចនេះ អ្នកនឹងមិនត្រូវបានគេស្គាល់ ឬនឹងកំណត់អត្តសញ្ញាណរបស់អ្នកឡើយ។
- អ្នកត្រូវបានស្វាគមន៍ក្នុងការផ្តល់លេខទូរស័ព្ទរបស់អ្នកនៅក្នុងសំណួរចុងក្រោយ។ ក្នុងករណីនោះ ទិន្នន័យនឹងមិនទុកជាអនាមិកទៀតទេ សម្រាប់មនុស្សដែលមានសិទ្ធិចូលប្រើទិន្នន័យដើម។ ទិន្នន័យរបស់អ្នកនៅតែអនាមិកជាសាធារណៈ ហើយនឹងមិនអាចកំណត់អត្តសញ្ញាណបានទេ។
- ទិន្នន័យនឹងត្រូវបានចែករំលែកជាសាធារណៈតែជារបាយការណ៍ និងការវិភាគសង្ខេបប៉ុណ្ណោះ។ ក្រៅពីនេះ ទិន្នន័យនឹងរក្សាជាការសម្ងាត់ទាំងអស់។
- អ្នកនឹងត្រូវផ្តល់ការយល់ព្រមសម្រាប់ការប្រមូលទិន្នន័យសម្រាប់ សមាគមស៊ីកាដា  ដើម្បីប្រមូល រក្សាទុក និងប្រើប្រាស់ទិន្នន័យរបស់អ្នកដោយស្របច្បាប់។
- មានតែអគ្គលេខាធិការនៃសមាគមស៊ីកាដា និងអ្នកប្រឹក្សាដោយមានកិច្ចសន្យាឯករាជ្យប៉ុណ្ណោះ  ដែលអាចប្រើប្រាស់ទិន្នន័យដើមនេះបាន។ ទិន្នន័យរបស់អ្នកនឹងមិនត្រូវបានចែករំលែក ឬលក់ឡើយ។

## Data Collection

Question: Do you agree to the collection, storage, processing, and public sharing of the data you will provide in this form?

- All data collected remain **anonymous**. You cannot be identified, nor will we make attempts to identify you.
- You are welcome to provide your phone number in the last question. In that case, the data will not be anonymous anymore to the people with access to the raw data. Your data remains anonymous publicly and will not be identifiable.
- Data will only be **shared publicly as summaries** and analyses, and is otherwise confidential.
- You will need to grant consent for data collection for CICADA to legally collect, store and use your data.
- Only the **CICADA Secretariat will have access to the raw data**, including independent contractors. Your data will not be shared or sold.

## សមាជិកភាពរបស់សមាគមស៊ីកាដា

### សំណួរៈ តើអ្នកជាសមាជិករបស់សមាគមស៊ីកាដាដែរឬទេ?

- ពាក្យពេញសមាគមស៊ីកាដា គឺ សមាគមដើម្បីការការអភិវឌ្ឍនិងការគាំទ្រវិស័យកៃច្នៃនៃកម្ពុជា។ សមាគមស៊ីកាដា ចង់មើលឃើញពីភាពចម្រុះ និងរីកចម្រើនសង្គមកម្ពុជា ដែលវិស័យវប្បធម៌ និងច្នៃប្រតិដ្ឋត្រូវបានទទួលស្គាល់ ឱ្យតម្លៃ និងរីកចម្រើន។ គោលបំណងរបស់សមាគមស៊ីកាដា  គឺដើម្បីតំណាង និងគៀងគររកការគាំទ្រសម្រាប់វិស័យវប្បធម៌ និងច្នៃប្រតិដ្ឋ ដើម្បីអភិវឌ្ឍរចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព និងរួមបញ្ចូល ដើម្បីធានាថា វិស័យរបស់យើងគឺជាចំណុចស្នូលនៃការសម្រេចចិត្តផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម។
- សមាគមស៊ីកាដា  គឺជាអង្គភាពសមាជិកភាពដែល**ទទួលយកទាំងសមាជិកភាពបុគ្គល និងស្ថាប័ន**។ អ្នកអាចឈ្វេងយល់បន្ថែមអំពីសមាជិកភាពសមាគមស៊ីកាដា  ដោយចុចនៅទីនេះ។

## CICADA Membership

### Question: Are you a member of CICADA?

- CICADA stands for *Creative Industries of Cambodia Association for Development and Advocacy*. CICADA envisions a diverse and flourishing Cambodian society where cultural and creative industries are recognized, valued, and thriving. CICADA's purpose is to represent and advocate for the cultural and creative industries to develop a sustainable and inclusive infrastructure to ensure that our sector is at the heart of political, economic and social decision-making.
- CICADA is a membership organisation that **accepts both individual and institutional membership**. You can learn more about CICADA membership here.

## ការរកប្រាក់ចំណេញ / មិនរកប្រាក់ចំណេញ

### សំណួរៈ តើអ្នកកំពុងធ្វើប្រតិបត្តិការដើម្បីរកប្រាក់ចំណេញ ឬមិនស្វែងរកប្រាក់ចំណេញ?

- អង្គភាពមិនមែនរដ្ឋាភិបាល (NGO) សមាគម មូលនិធិ សហគ្រាសសង្គម និងស្ថាប័នសាធារណៈ គឺជាអង្គភាពមិនរកប្រាក់ចំណូល/មិនស្វែងរកប្រាក់ចំណូល។ ពួកគេវិនិយោគប្រាក់ចំណេញទាំងអស់ឡើងវិញទៅក្នុងកម្មវត្ថុរបស់អង្គភាព។
- ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត សហគ្រាសឯកបុគ្គល ដៃគូ និងក្រុមហ៊ុនផ្សេងទៀតគឺជាអង្គភាពរកប្រាក់ចំណូល។ ប្រាក់ចំណេញជាទូទៅត្រូវបានប្រើប្រាស់សម្រាប់ផលប្រយោជន៍បុគ្គល។
- ប្រសិនបើអ្នកមិនត្រូវបានចុះឈ្មោះអង្គភាពជាផ្លូវការទេ សូមកំណត់ថាតើប្រាក់ចំណេញរបស់អ្នកគឺសម្រាប់ប្រាក់ចំណេញបុគ្គល (សម្រាប់ប្រាក់ចំណេញ) ឬត្រលប់ទៅអង្គភាពវិញទាំងស្រុង (មិនស្វែងរកប្រាក់ចំណេញ) សម្រាប់សកម្មភាពនាពេលអនាគត។

## For Profit / Not-for-Profit

### Question: Are you operating for-profit or not-for-profit?

- Non-governmental organisations (NGO), associations, foundations, social enterprises and public institutions are non-profit / not-for-profit entities. They reinvest all profits back into the organisation’s objectives.
- Limited liability companies, sole proprietorship, partnerships, and other companies are for-profit entities. Profits are generally used for individual gain.
- If you are not formally registered, please determine whether your profits are for individual gain (for-profit) or go entirely back into the organisation (not-for-profit) for future activities.

## ទីតាំង

### សំណួរ៖ តើអ្នកមានទីតាំង/ប្រតិបត្តិការនៅខេត្តណា?

- ជាទូទៅ នេះគឺជា**ខេត្តដែលអ្នកបានចុះឈ្មោះអង្គភាពជាផ្លូវការ និង/ឬមានទីស្នាក់ការកណ្តាល**។
- ប្រសិនបើអ្នកមានទីស្នាក់ការច្រើនជាងមួយ សូមជ្រើសរើសខេត្តដែលសំខាន់បំផុតសម្រាប់ការងាររបស់អ្នក។

## Location

### Question: In which province are you based / operate in?

- Generally, this is the **province in which you are registered and/or have your headquarters**.
- If you operate in more than province, please select the most important province for your work.

## វិស័យចម្បង

### សំណួរ៖ តើវិស័យមួយណាជាវិស័យចម្បងរបស់អ្នកដែលអ្នកធ្វើប្រតិបត្តិការ?

- សូមជ្រើសរើសវិស័យសំខាន់បំផុតសម្រាប់ការងាររបស់អ្នក។
- អ្នកអាចជ្រើសរើសផ្នែកបន្ថែមនៅក្នុងសំណួរបន្ទាប់ ប្រសិនបើអ្នកដំណើរការក្នុងវិស័យជាច្រើន។
- គិតអំពី**ជំនាញ/វិស័យរបស់អ្នកជាចម្បង ជាជាងមុខងាររបស់អ្នក**។ ប្រសិនបើអ្នកដំណើរការមហោស្រពតន្ត្រី សូមជ្រើសរើសតន្ត្រី (មិនមែនមហោស្រព)។ ប្រសិនបើអ្នកជាឈ្មួញកណ្តាលសម្រាប់រូបចម្លាក់សហសម័យ សូមជ្រើសរើសសិល្បៈចក្ខុទស្សន៍ (មិនមែនភ្នាក់ងារ CCI)។ ប្រសិនបើអ្នកជាបណ្ណសារភាពយន្ត សូមជ្រើសរើសខ្សែភាពយន្ត (មិនមែនបណ្ណសារ)។ ប្រសិនបើអ្នកជាអ្នកតំឡើងឈុតល្ខោន សូមជ្រើសរើសសិល្បៈសម្តែង/ទស្សនីយភាព (មិនមែនឌីហ្សាញ និងសេវាកម្មច្នៃប្រតិដ្ឋ)
- ខាងក្រោមនេះជាការពន្យល់សម្រាប់ប្រភេទនីមួយៗ៖

- **សិល្បៈទស្សនីយភាព** រួមបញ្ចូលគ្រប់ទម្រង់នៃល្ខោន របាំ សៀក ក៏ដូចជាសិល្បៈសម្តែងផ្សេងទៀត។
- **តន្ត្រី** រួមបញ្ចូលគ្រប់ទម្រង់នៃការផលិតតន្ត្រី ការថតសំឡេង ទស្សនាចរ ការចាក់ផ្សាយ ការអប់រំ ព្រមទាំងឧបករណ៍ដែលគាំទ្រការបង្កើតសេវាកម្មនានា។
- **សិល្បៈគំនូរ** រួមបញ្ចូលគ្រប់ទម្រង់នៃគំនូរ ចម្លាក់ ការដំឡើង ការថតរូប និងវីដេអូសិល្បៈ។
- **សោតទស្សន៍** រួមបញ្ចូលគ្រប់ទម្រង់នៃខ្សែភាពយន្ត គំនូរជីវចល សិល្បៈគូរ និងវីដេអូហ្គេម។
- **អក្សរសិល្ប៍ និងបោះពុម្ពផ្សាយ** រួមបញ្ចូលគ្រប់ទម្រង់នៃសៀវភៅ ទស្សនាវដ្តី កំណាព្យ ស្ទ្រីប អំណាន និងការបោះពុម្ពផ្សាយលើអ៊ិនធឺនែត
- **សិប្បកម្ម និងសិល្បៈធ្វើម្ហូប** រួមបញ្ចូលគ្រប់ទម្រង់នៃឈើ ដែក ស្បែក គ្រឿងស្មូន តម្បាញ និងគ្រឿងអលង្ការ ព្រមទាំងសិល្បៈធ្វើម្ហូបផងដែរ។
- **បេតិកភណ្ឌ សារមន្ទីរ បណ្ណាល័យ បណ្ណសារ** រួមមានទាំងបេតិកភណ្ឌវប្បធម៌ និងផ្នែកធម្មជាតិ ក៏ដូចជាបុរាណវិទ្យាផងដែរ។
- **ភ្នាក់ងារ CCI** រួមបញ្ចូលគ្រប់ទម្រង់នៃការគ្រប់គ្រងព្រឹត្តិការណ៍ និងមហោស្រព ការអភិវឌ្ឍន៍វិជ្ជាជីវៈ និងអ្នកផ្តល់ការបណ្តុះបណ្តាល ស្ថាប័នផ្តល់ជំនួយ ស្ថាប័នគៀងគរកការគាំទ្រ ក៏ដូចជាសេវាកម្មគាំទ្រ សម្រាប់វិស័យវប្បធម៌ និងច្នៃប្រតិដ្ឋ។
- **ការផ្សព្វផ្សាយលើទូរទស្សន៍ និងវិទ្យុ** រួមបញ្ចូលគ្រប់ទម្រង់នៃការរចនាការផ្សាយពាណិជ្ជកម្ម ទូរទស្សន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយអនឡាញ និងវីដេអូហ្គេមដែលផ្តល់ហិរញ្ញប្បទានជាចម្បងតាមរយៈការផ្សាយពាណិជ្ជកម្មបែបប្រពៃណី។
- **អ្នកបង្កើត / អ្នកមានឥទ្ធិពលសេដ្ឋកិច្ច** រួមបញ្ចូលការដំណើរការផតខាស ប៉ុស្តិ៍វីដេអូ បណ្តាញផ្សាយផ្ទាល់ និងសហគមន៍អនឡាញដែលផ្អែកលើម៉ាកច្នៃប្រតិដ្ឋបុគ្គល និងបើកការទំនាក់ទំនងពីរផ្លូវជាមួយអ្នកតាមដាន។ ប្រភពចំណូលច្រើនតែជាប្រភពចម្រុះនៃប្រាក់ចំណូលពីការផ្សាយពាណិជ្ជកម្ម ការឧបត្ថម្ភម៉ាកយីហោ ការផ្តល់ជំនួយខ្នាតតូច និងការជាវសេវាកម្ម។
- **ឌីហ្សាញ និងសេវាកម្មច្នៃប្រតិដ្ឋ** រួមបញ្ចូលគ្រប់ទម្រង់នៃការរចនាម៉ូដ ការរចនារូបភាព និងក្រាហ្វិក ការរចនាផលិតផលប្រកបដោយភាពច្នៃប្រតិដ្ឋ ក៏ដូចជាការរចនាខាងក្នុង និងស្ថាបត្យកម្ម។

## Primary Sector

### Question: Which is your primary sector that you operate in?

- Please select the sector most important for your work.
- You can select additional sectors in the next question if you operate in multiple sectors.

- Think primarily of your **discipline / industry rather than your function**. If you run a music festival, please select *music* (and not *festival*). If you are a broker for contemporary sculptures, please select *visual arts* (and not *CCI agency*). If you are a film archive, please select *film* (and not *archive*). If you are a *theatre set designer*, please select performing arts (and not *design and creative services*)
- Here are non-exhaustive explanations for each category:
    - **Performing Arts** include all forms of theatre, dance, circus, as well as performance art.
    - **Music** includes all forms of music production, recording, touring, streaming, education, as well as instrument making and support services.
    - **Visual arts** include all forms of painting, sculpture, installation, photography, and video art.
    - **Audiovisual** includes all forms of film, animation, and artful video games.
    - **Literature and publishing** include all forms of books, magazines, poetry, scripts, readings, and online publishing.
    - **Crafts and culinary arts** include all forms of wood, metal, leather, pottery, weaving, and jewellery, as well as culinary arts.
    - **Heritage, museums, libraries, archives** may also include both cultural and natural heritage sites as well as archaeological sites.
    - **CCI agencies** include all forms of event and festival management, professional development and training providers, grantmaking institutions, advocacy bodies, as well as incubation services for the cultural and creative industries.
    - **Advertising, TV and radio** include all forms of advertising design, television, radio, and online broadcast media and video games primarily financed through traditional advertisement.
    - **Creator / influencer economy** includes the running of podcasts, video channels, live streaming channels, and online communities that are based around an individual creative brand and enable two-way communication with followers. Revenue sources are often a mix of advertising revenue, brand sponsorships, micro tipping, and subscription services.
    - **Design and creative services** include all forms of fashion design, visual and graphic design, creative product design, as well as interior design and architecture.

## វិស័យបន្ទាប់បន្សំ

### សំណួរ៖ ប្រសិនបើមាន តើវិស័យមួយណាទៀត ដែលអ្នកកំពុងធ្វើប្រតិបត្តិការ?

- ប្រសិនបើអ្នកធ្វើប្រតិបត្តិការក្នុងវិស័យបន្ថែម អ្នកអាចជ្រើសរើស**វិស័យជាច្រើនតាមដែលអ្នកធ្វើប្រតិបត្តិការ។**

## Secondary Sector

### Question: If any, what other sectors do you operate in?

- If you operate in additional sectors, you may select **as many sectors as you operate in**.

## ការចុះឈ្មោះអង្គភាពជាផ្លូវការ

### សំណួរ៖ តើអ្នកចុះឈ្មោះជាផ្លូវការដែរឬទេ?

- ការចុះឈ្មោះអង្គភាពជាផ្លូវការមានន័យថាអ្នកបានដាក់ឯកសារចាំបាច់ជាមួយក្រសួងពាក់ព័ន្ធ និង/ឬ អគ្គនាយកដ្ឋានពន្ធដារ (GDT) ហើយត្រូវបានអនុញ្ញាតជាផ្លូវការដោយអាជ្ញាធរទាំងនេះ។
- ប្រសិនបើអ្នកមានដូចខាងក្រោម អ្នកត្រូវបានចាត់ទុកថាបានចុះឈ្មោះអង្គភាពជាផ្លូវការ៖ ពន្ធប៉ាតង់ ការចុះបញ្ជីក្រុមហ៊ុន ការចុះ MoU ជាមួយក្រសួងមួយ ឬច្រើនទាក់ទងនឹងអត្ថិភាពរបស់អ្នក។

## Registration

### Question: Are you formally registered?

- A formal registration means you have filed the necessary paperwork with the relevant ministries and/or the General Department of Taxation (GDT), and have been **officially approved by these authorities**.
- If you have any of the following, you are considered registered: tax patent, company registration, MoU with one or more ministries regarding your existence.

## ប្រភេទនៃការចុះឈ្មោះអង្គភាពជាផ្លូវការ

### សំណួរ៖ តើអ្នកមានការចុះឈ្មោះប្រភេទណា?

- សូមជ្រើសរើសប្រភេទនៃការចុះឈ្មោះអង្គភាពជាផ្លូវការ
- ប្រសិនបើអ្នកមានការចុះឈ្មោះអង្គភាពច្រើនជាងមួយ (ឧ. អង្គភាពក្រៅរដ្ឋាភិបាលបរទេស និងក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ឬអង្គភាពក្រៅរដ្ឋាភិបាលបរទេស និងសមាគមក្នុងស្រុក) **សូមបំពេញទម្រង់បែបបទនេះសម្រាប់អង្គភាពនីមួយៗដាច់ដោយឡែកពីគ្នា។**

## Type of Registration

### Question: What type of registration do you have?

- Please select your type of registration.
- If you have more than one registration (e.g. a Foreign NGO and a Limited Liability Company, or a Foreign NGO and a Local Association), please **complete this form for each organisation separately**.

## ប្រាក់ចំណូលសរុប

សំណួរ៖ តើប្រាក់ចំណូលរបស់អ្នកក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២២ មានចំនួនប៉ុន្មាន?

- ប្រាក់ចំណូលគឺជាប្រាក់ចំណូលសរុបនៃអង្គភាពរបស់អ្នក។ នេះអាចរួមបញ្ចូលការលក់ មូលនិធិ និងប្រភពចំណូលផ្សេងទៀត។
- ប្រាក់ចំណូលគឺជាប្រាក់ចំណូលមុនពេលកាត់ការចំណាយ និងថ្លៃពន្ធនានា។

## Revenue

Question: What was your revenue in 1st or 2nd Semester of the year?

- Revenue is the **total income** of your organisation. This might include sales, grants, and other sources of income.
- Revenue is your **income before you deduct any expenses or taxes**.

## ប្រាក់ចំណូលក្នុងស្រុក

សំណួរ៖ តើភាគរយនៃប្រាក់ចំណូលសរុបរបស់អ្នកបានមកពីប្រទេសកម្ពុជាប៉ុន្មាន? (ឧ. ចំណូលក្នុងស្រុក)

- ប្រាក់ចំណូលក្នុងស្រុករាប់តែចំណូលដែលអ្នករកបាននៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។ នេះរាប់បញ្ចូលទាំងប្រាក់ចំណូលពីបុគ្គល និងអង្គភាពក្នុងស្រុក និងបរទេស ដែលធ្វើប្រតិបត្តិការក្នុង និង/ឬអនុវត្តផ្ទាល់ក្នុងប្រទេសកម្ពុជា។
- ការលក់ មូលនិធិ និងប្រភពចំណូលផ្សេងទៀតពីក្រៅប្រទេសកម្ពុជា មិនត្រូវបានរាប់បញ្ចូលក្នុងប្រភេទនេះទេ។
- អ្នកអាចប៉ាន់ស្មានភាគរយបាន។

## Domestic Revenue

Question: What percentage of your total revenue was from within Cambodia? (i.e. domestic revenue)

- Domestic revenue **only counts income you make in Cambodia**. This includes income from local and foreign individuals and organisations who operate in and/or physically are in Cambodia.
- Sales, grants, and other sources of income from outside Cambodia are excluded in this category.
- You may estimate the percentage.

## ចំណូលចេញពីសកម្មភាពវប្បធម៌

សំណួរ៖ តើភាគរយនៃប្រាក់ចំណូលសរុបរបស់អ្នកបានមកពីសកម្មភាពវប្បធម៌មានចំនួនប៉ុន្មាន?

- ប្រាក់ចំណូលពីសកម្មភាពវប្បធម៌ មានន័យថាអ្នកគ្រាន់តែរាប់**ប្រាក់ចំណូលពីការអនុវត្តវប្បធម៌ស្នូល ឬការច្នៃប្រតិដ្ឋនៃអង្គភាពរបស់អ្នក**។ សកម្មភាពពាណិជ្ជកម្មណាមួយក្រៅពីបេសកកម្មវប្បធម៌ ឬគំនិតច្នៃប្រតិដ្ឋរបស់អ្នក មិនត្រូវបានរាប់បញ្ចូលក្នុងប្រភេទនេះទេ។
- សកម្មភាពវប្បធម៌<u>មិនត្រូវ</u>រាប់បញ្ចូលនូវការលក់ពាណិជ្ជកម្ម ឬការបង្កើតប្រាក់ចំណូលដែលមិនមែនជាផ្នែកនៃការអនុវត្តវប្បធម៌ស្នូល ឬគំនិតច្នៃប្រតិដ្ឋរបស់អ្នកឡើយ។
- ជាឧទាហរណ៍ ថាមានអង្គភាពសម្តែងទស្សនីយភាពមួយ បានផលិតកម្មវិធីសម្តែង ហើយក៏បើកអាជីវកម្មភោជនីយដ្ឋានសម្រាប់អាហារសម្រន់មុនកម្មវិធី។ ការលក់សំបុត្រសម្រាប់ការសម្តែងមានលក្ខណៈគ្រប់គ្រាន់ជាសកម្មភាពវប្បធម៌ ប៉ុន្តែការលក់អាហារ និងភេសជ្ជៈនៅភោជនីយដ្ឋានមិនមានលក្ខណៈគ្រប់គ្រាន់ជាសកម្មភាពវប្បធម៌នោះទេ។

## Revenue from Cultural Activity

Question: What percentage of your total revenue resulted from cultural activity?

- Revenue from cultural activity means that you only count **income from the core cultural or creative practice of your organisation**. Any commercial activities outside of your cultural or creative mission are excluded in this category.
- Cultural activity <u>must not</u> include any commercial sales or income generation that are not part of your core cultural or creative practice.
- For example: A performing arts organisation produces shows and also runs a restaurant business for pre-show snacks. Ticket sales for the performance qualify as cultural activity, selling food and drinks at the restaurant do not qualify as cultural activity.

## ចំណូលចេញពីឧស្សាហ៍កម្មទេសចរណ៍

សំណួរ៖ តើភាគរយនៃប្រាក់ចំណូលសរុបរបស់អ្នកមានចំនួនប៉ុន្មាន ដែលរកបានតាមរយៈវិស័យទេសចរណ៍?

- ប្រាក់ចំណូលពីវិស័យទេសចរណ៍រាប់បញ្ចូលតែការលក់ ការបរិច្ចាគ មូលនិធិ និងប្រាក់ចំណូលផ្សេងទៀតពីបុគ្គល និងអង្គភាពដែលដំណើរការជាចម្បងក្នុងវិស័យទេសចរណ៍។
- នេះអាចរួមបញ្ចូលប្រាក់ចំណូលពីការលក់សំបុត្រតាមរយៈប្រតិបត្តិករទេសចរណ៍ ការបរិច្ចាគពីទេសចរម្នាក់ៗ កិច្ចសន្យារចនាក្រាហ្វិកសម្រាប់សណ្ឋាគារ ការផលិតវីដេអូសម្រាប់ក្រុមហ៊ុនអាកាសចរណ៍ និងស្ថិតក្នុងទម្រង់ផ្សេងៗទៀត។
- ប្រាក់ចំណូលពីវិស័យទេសចរណ៍ អាចរាប់បញ្ចូលទាំងចំណូលពីសកម្មភាពវប្បធម៌ និងមិនមែនវប្បធម៌ ក៏ដូចជាចំណូលក្នុងស្រុក និងអន្តរជាតិ។

## Revenue from Tourism Industry

### Question: What percentage of your total revenue was generated through the tourism industry?

- Revenue from the tourism industry only counts sales, donations, grants and other income from individuals and organisations that are primarily operating in the tourism sector.
- This may include income from ticket sales through tour operators, donations from individual tourists, graphic design contracts for hotels, video production for airlines, and many other forms.
- Revenue from the tourism industry may include revenue from cultural and non-cultural activity, as well as domestic and international revenue.

## អំពីពន្ធ

### សំណួរ៖ តើអ្នកបង់ពន្ធដែរឬទេ?

- ប្រសិនបើស្ថាប័នរបស់**អ្នកបង់ពន្ធខាងក្រោមជាប្រចាំ** សូមជ្រើសរើស 'បាទ/ចាស'៖ ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់ខែ ពន្ធកាត់ទុក (អ្នកទិញទុកដើម្បីបង់ពន្ធជូនរដ្ឋាភិបាល) អាករពិសេសលើការកម្សាន្ត ពន្ធសាជីវកម្មផ្សេងទៀត។

## Taxes

### Question: Do you pay any taxes?

- If your organisation **regularly pays any of the following taxes**, please select 'yes': income tax, tax on profit, salary tax, withholding tax (withheld by the buyer to pay tax to government), specific tax on entertainment, any other corporate taxes.

## អំពីប្រាក់ចំណូលជាប់ពន្ធ

### សំណួរ៖ តើភាគរយនៃប្រាក់ចំណូលសរុបរបស់អ្នកត្រូវបានបង់ពន្ធប៉ុន្មាន?

- ប្រសិនបើអ្នកគ្រាន់តែប្រកាសជាផ្លូវការនូវផ្នែកនៃប្រាក់ចំណូលរបស់អ្នក **សូមចែករំលែកភាគរយប៉ាន់ស្មាននៃប្រាក់ចំណូលដែលអ្នកបានប្រកាស។**
- អង្គភាពខ្លះអាចមានប្រាក់ចំណូលក្រៅផ្លូវការ (មិនមានបង្កាន់ដៃ) ហើយជ្រើសរើសមិនប្រកាស។ ប្រាក់ចំណូលក្រៅផ្លូវការនេះនឹងមិនត្រូវបានយកពន្ធទេ។
- ក្នុងករណីអ្នកប្រកាសនូវគ្រប់ប្រាក់ចំណូល នោះអ្នកត្រូវដាក់បញ្ចូលលេខ ១០០ (ភាគរយ) នៅក្នុងចម្លើយរបស់អ្នក

## Taxed Revenue

### Question: What percentage of your total revenue was taxed?

- If you only officially declare part of your revenue, please share an **estimate percentage of the revenue you have declared** and that was subsequently taxed.

- Some organisations might have informal income (no receipts) and choose not to declare it. This informal income will not be taxed.
- If you declare all of your revenue, you need to fill in '100'.

## ការលក់ទៅអ្នកទិញនៅក្រៅប្រទេស (ការនាំចេញផលិតផលវប្បធម៌ និងច្នៃប្រតិដ្ឋ)

សំណួរ៖ តើអ្នកលក់ផលិតផលវប្បធម៌ទៅទីតាំងក្រៅប្រទេសជាលក្ខណៈអន្តរជាតិដែរឬទេ?

- ការលក់មានលក្ខណៈអន្តរជាតិ លុះត្រាតែអ្នកទិញមានមូលដ្ឋាននៅក្រៅប្រទេសកម្ពុជា គាត់មិនបានមកជាទេសចរ ហើយទិញផលិតផលរបស់យើងនៅកម្ពុជាទេ មានន័យថាខ្លួនគាត់ផ្ទាល់មិនមែនជាទេសចរមកទិញផលិតផលវប្បធម៌នៅកម្ពុជាទេ។
- ផលិតផលវប្បធម៌រួមមានទាំងទំនិញវប្បធម៌/ច្នៃប្រតិដ្ឋ និងសេវាកម្មវប្បធម៌/ច្នៃប្រតិដ្ឋ។

## International Sales

Question: Do you sell cultural products internationally?

- A sale is only international if the **buyer is based outside of Cambodia**.
- Cultural products include both cultural / creative goods and cultural / creative services.

## តំបន់នាំចេញ

សំណួរ៖ តើអ្នកលក់ផលិតផលវប្បធម៌របស់អ្នកច្រើនបំផុតនៅតំបន់ណា ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២២ កន្លងមកនេះ?

- ប្រសិនបើអ្នកមានការលក់បែបអន្តរជាតិ សូមកំណត់តំបន់ដែលអ្នកលក់ផលិតផលវប្បធម៌ដើម្បីទទួលបានចំណូលពីការលក់សរុបខ្ពស់បំផុត។
- ឧទាហរណ៍៖ ប្រសិនបើអ្នកលក់ផលិតផល ៥ ទៅកាន់ប្រទេសអាស៊ានក្នុងតម្លៃសរុប ១០ ដុល្លារ និងផលិតផល ២ ទៅកាន់ប្រទេស ក្នុងសហភាពអឺរ៉ុបក្នុងតម្លៃសរុប ២០ ដុល្លារ។ សូមជ្រើសរើសតំបន់សហភាពអឺរ៉ុប 'EU' ព្រោះផលិតផលនាំចេញរបស់អ្នកលក់បានតម្លៃខ្ពស់ជាងលក់ក្នុងតំបន់អាស៊ី។

## Export Regions

Question: What was your top export region in 1st or 2nd Semester of the year?

- If you have international sales, identify the **region in which you sell cultural products for the highest total sales income**.
- For example: If you sell 5 products to ASEAN countries for a total of $10, and 2 products to EU countries for a total of $20, please select the top export region 'EU'.

## សហប្រតិបត្តិការអន្តរជាតិ

សំណួរ៖ តើអ្នកបានចូលរួមសហការអន្តរជាតិថ្មីៗប៉ុន្មានក្នុងអំឡុងពេល ៦ខែដើមឆ្នាំ២០២២ កន្លងមកនេះ?

- កិច្ចសហការជាអន្តរជាតិ គឺជាការងារទាំងឡាយណាដែលអ្នកបានចូលមកកាន់ជាផ្នែកនៃក្រុម ឬសមាគមជាមួយអង្គភាព និងបុគ្គលដែលនៅក្រៅប្រទេសកម្ពុជា។ កិច្ចសហប្រតិបត្តិការជាមួយបុគ្គល ឬអង្គភាពបរទេសមិនរាប់បញ្ចូលក្នុងប្រភេទនេះទេ។
- កិច្ចសហប្រតិបត្តិការអន្តរជាតិអាចរួមបញ្ចូលមានដូចជា សហផលិត សហគម្រោង សម្ព័ន្ធការងារប្រឹក្សារួម ។ល។

## International Collaborations

Question: How many new international collaborations did you participate in during 1st half of 2022?

- An international collaboration is any work that you approached **as part of a team or consortium with organisations and individuals outside of Cambodia**. Collaboration with foreign individuals or organisations do not count in this category.
- International collaborations may include co-productions, co-created projects, consortium consulting work etc.

## ផលិតផលវប្បធម៌

សំណួរ៖ តើផលិតផលវប្បធម៌ប៉ុន្មានដែលអ្នកបានបង្កើត/ផលិត/រចនា/ត្រូវបានចេញផ្សាយ/ចាក់បញ្ចាំងក្នុងរយៈពេល ៦ ខែដើមឆ្នាំ កន្លងមកនេះ?

- ផលិតផលវប្បធម៌រួមមាន**ទាំងទំនិញវប្បធម៌/ច្នៃប្រតិដ្ឋ និងសេវាកម្មវប្បធម៌/ច្នៃប្រតិដ្ឋ**។
- ផលិតផលវប្បធម៌អាចមានទាំងរូបី (ឧ. ការរចនាគ្រឿងអលង្ការ) និងអរូបី (ឧ. ការដំឡើងរបាំ)។
- ការងារសិល្បៈដែលត្រូវបានផ្តល់ទុនដើម្បីដំឡើងដោយអ្នកបញ្ជាទិញសេវាកម្មសិល្បៈ គឺរាប់តែសិល្បករ/អ្នកនិពន្ធ/អ្នកបង្កើតប៉ុណ្ណោះ ប៉ុន្តែមិនមែនសម្រាប់អ្នកបញ្ជាទិញសេវាកម្មសិល្បៈនោះទេ។

## Cultural Products

Question: How many cultural products that you have created / produced / designed were released / premiered in 1st half of 2022?

- Cultural products include **both cultural / creative goods and cultural / creative services**.
- Cultural products can be both tangible (e.g. jewellery design) and intangible (e.g. choreography).
- Commissioned work only counts for the artists / author / creator, but not for the commissioner.

## ការចុះបញ្ជីកម្មសិទ្ធិបញ្ញា

សំណួរ៖ តើអ្នកបានចុះបញ្ជីផលិតផលវប្បធម៌ណាមួយជាកម្មសិទ្ធិបញ្ញាក្នុងរយៈពេល ៦ ខែដើមឆ្នាំ២០២២ កន្លងមកដែរឬទេ?

- ផលិតផលវប្បធម៌នៃបុគ្គល និងផលិតផលច្នៃប្រតិដ្ឋ អាចត្រូវបានចុះបញ្ជីជាកម្មសិទ្ធិបញ្ញាដើម្បីការពារការលួចគំនិត ការច្នៃប្រតិដ្ឋ ការរចនា និងការងារសិល្បៈ។
- ផលិតផលវប្បធម៌រួមមានទាំងទំនិញវប្បធម៌/ច្នៃប្រតិដ្ឋ និងសេវាកម្មវប្បធម៌/ច្នៃប្រតិដ្ឋ។
- រក្សាសិទ្ធិ គឺជាទម្រង់នៃកម្មសិទ្ធិបញ្ញា ប្រសិនបើអ្នកបានចុះបញ្ជីការរក្សាសិទ្ធិសម្រាប់ផលិតផលវប្បធម៌ណាមួយរបស់អ្នក នោះអ្នកបានចុះបញ្ជីវាដោយស្វ័យប្រវត្តិជាកម្មសិទ្ធិបញ្ញារបស់អ្នក។

## Intellectual Property Registration

Question: Have you registered any cultural products as intellectual property in 1st half of 2022?

- Individual cultural and creative products can be registered as intellectual property to prevent theft of ideas, inventions, designs, and artistic work.
- Cultural products include both cultural / creative goods and cultural / creative services.
- Copyright is a form of intellectual property; if you have registered copyright for any of your cultural products, you have automatically registered it as your intellectual property.

## កម្មសិទ្ធិបញ្ញានៅកម្ពុជា

សំណួរ៖ តើផលិតផលវប្បធម៌ប៉ុន្មានដែលអ្នកបានចុះបញ្ជីជាកម្មសិទ្ធិបញ្ញានៅកម្ពុជា ក្នុងរយៈពេល ៦ខែដើមឆ្នាំ ២០២២ កន្លងមកនេះ?

- នៅក្នុងប្រទេសកម្ពុជា កម្មសិទ្ធិបញ្ញាអាចចុះបញ្ជីនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (MoCFA) និងក្រសួងពាណិជ្ជកម្ម (MoC)។
- ផលិតផលវប្បធម៌ និងគំនិតច្នៃប្រតិដ្ឋបុគ្គលអាចត្រូវបានចុះបញ្ជីជាកម្មសិទ្ធិបញ្ញា ដើម្បីការពារការលួចគំនិត ការច្នៃប្រតិដ្ឋ ការរចនា និងការងារសិល្បៈ។
- ផលិតផលវប្បធម៌រួមមានទាំងទំនិញវប្បធម៌/ច្នៃប្រតិដ្ឋ និងសេវាកម្មវប្បធម៌/ច្នៃប្រតិដ្ឋ។

## Intellectual Property in Cambodia

Question: How many cultural products have you registered as intellectual property in Cambodia in the 1st half of 2022?

- In Cambodia, intellectual property can be registered at the Ministry of Culture and Fine Arts (MoCFA) and the Ministry of Commerce (MoC).
- Individual cultural and creative products can be registered as intellectual property to prevent theft of ideas, inventions, designs, and artistic work.
- Cultural products include both cultural / creative goods and cultural / creative services.

## កម្មសិទ្ធិបញ្ញានៅក្រៅប្រទេស

សំណួរ៖ តើផលិតផលវប្បធម៌ប៉ុន្មានដែលអ្នកបានចុះបញ្ជីជាកម្មសិទ្ធិបញ្ញានៅបរទេសក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២២ កន្លងមកនេះ?

- ប្រសិនបើអ្នកបានចុះបញ្ជីការងារណាមួយរបស់អ្នកជាកម្មសិទ្ធិបញ្ញានៅខាងក្រៅប្រទេសកម្ពុជា សូមជ្រើសរើសចំនួនស្នាដៃ។
- ផលិតផលវប្បធម៌ និងគំនិតច្នៃប្រតិដ្ឋបុគ្គលអាចត្រូវបានចុះបញ្ជីជាកម្មសិទ្ធិបញ្ញាដើម្បីការពារការលួចគំនិត ការច្នៃប្រតិដ្ឋ ការរចនា និងការងារសិល្បៈ។
- ផលិតផលវប្បធម៌រួមមានទាំងទំនិញវប្បធម៌/ច្នៃប្រតិដ្ឋ និងសេវាកម្មវប្បធម៌/ច្នៃប្រតិដ្ឋ។

## Intellectual Property Abroad

Question: How many cultural products have you registered as intellectual property abroad in 1st half of 2022?

- If you have registered any of your work as intellectual property outside of Cambodia, please select the number of works.
- Individual cultural and creative products can be registered as intellectual property to prevent theft of ideas, inventions, designs, and artistic work.
- Cultural products include both cultural / creative goods and cultural / creative services.

## ប្រទេសកម្មសិទ្ធិបញ្ញា

សំណួរ៖ តើអ្នកបានចុះបញ្ជីផលិតផលវប្បធម៌ជាកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសណា?

- ប្រាប់ឈ្មោះប្រទេសទាំងអស់ដែលអ្នកបានចុះបញ្ជីកម្មសិទ្ធិបញ្ញានៅខាងក្រៅប្រទេសកម្ពុជា។
- ផលិតផលវប្បធម៌ និងគំនិតច្នៃប្រតិដ្ឋបុគ្គលអាចត្រូវបានចុះបញ្ជីជាកម្មសិទ្ធិបញ្ញាដើម្បីការពារការលួចគំនិត ការច្នៃប្រតិដ្ឋ ការរចនា និងការងារសិល្បៈ។
- ផលិតផលវប្បធម៌រួមមានទាំងទំនិញវប្បធម៌/ច្នៃប្រតិដ្ឋ និងសេវាកម្មវប្បធម៌/ច្នៃប្រតិដ្ឋ។

## Intellectual Property Countries

Question: In which country/countries have you registered cultural products as intellectual property?

- Name all the countries in which you have registered intellectual property outside of Cambodia.
- Individual cultural and creative products can be registered as intellectual property to prevent theft of ideas, inventions, designs, and artistic work.
- Cultural products include both cultural / creative goods and cultural / creative services.

## ផលិតផលវប្បធម៌បែបឌីជីថល

សំណួរៈ តើអ្នកលក់ផលិតផលវប្បធម៌បែបឌីជីថលដែរឬទេ?

- ផលិតផលវប្បធម៌បែបឌីជីថលរួមមានទាំងទំនិញវប្បធម៌/ការច្នៃប្រតិដ្ឋ និងសេវាកម្មវប្បធម៌/ច្នៃប្រតិដ្ឋ ដែលជាឌីជីថល/និម្មិតក្នុងទម្រង់របស់វា។

## Digital Cultural Products

Question: Do you sell digital cultural products?

- Digital cultural products include both cultural / creative goods and cultural / creative services that are digital / virtual in its form.

## ទីកន្លែងរូបវន្ត

សំណួរៈ តើអ្នកមានទីកន្លែងរូបវន្តដែរឬទេ? (ក្រៅពីការិយាល័យ)

- កន្លែងវប្បធម៌រូបវន្ត រួមមាន រោងមហោស្រព ឆាក ស្ទូឌីយោ វិចិត្រសាល បណ្ណាល័យ បណ្ណសារ បន្ទប់តាំងបង្ហាញ។ល។
- ដាក់ឈ្មោះតែទីកន្លែង**អចិន្ត្រៃយ៍ ឬពាក់កណ្តាលអចិន្ត្រៃយ៍** ដែលអ្នករក្សា ឬចែករំលែកជាមួយតួអង្គផ្សេងទៀត។
- ការិយាល័យមិនរាប់បញ្ចូលក្នុងប្រភេទនេះទេ។ ការិយាល័យដែលមានកន្លែងច្នៃប្រតិដ្ឋ ដូចជាស្ទូឌីយ៉ូរបស់សិល្បករ ឬបន្ទប់ហាត់សមអាចត្រូវបានរាប់។

## Physical Space

Question: Do you maintain a physical space? (Except for an office)

- Physical cultural spaces include theatres, stages, studios, galleries, libraries, archives, showrooms etc.
- Only name **permanent or semi-permanent spaces** that you maintain or share with other actors.
- Offices do not count in this category. Offices that also feature creative spaces such as an artist studio or a rehearsal room can be counted.

## ភ្ញៀវសញ្ជាតិកម្ពុជា

សំណួរៈ តើភាគរយនៃភ្ញៀវ/អតិថិជន របស់អ្នកជាសញ្ជាតិកម្ពុជាប៉ុន្មានភាគរយ?

- "កម្ពុជា" មិនត្រូវបានកំណត់វិសាលភាពឱ្យបានច្បាស់លាស់។ សូមរាប់មនុស្សដែលជាទូទៅរស់នៅក្នុងប្រទេសកម្ពុជា ដោយមិនរាប់បញ្ចូលជនបរទេស និងទេសចរ។
- លោកអ្នកអាចប៉ាន់ស្មានបាន។

## Cambodian Visitors

Question: What percentage of your visitors / customers / clients have been Cambodian?

- ‘Cambodian’ is not strictly defined. Please count people who **generally reside in Cambodia**, excluding foreign expats and tourists.
- Estimates are fine.

## ការបណ្តុះបណ្តាលដែលបានរៀបចំ

សំណួរ៖ តើអ្នកបានរៀបចំវគ្គបណ្តុះបណ្តាល/សិក្ខាសាលាចំនួនប៉ុន្មានក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២២កន្លងមកនេះ?

- នៅក្នុងប្រភេទនេះ គឺរាប់សកម្មភាពអភិវឌ្ឍន៍ជំនាញទាំងអស់ដែលអ្នកបានរៀបចំ ជាម្ចាស់ផ្ទះ ទាំងខាងក្នុង និងខាងក្រៅកន្លែងការងារ។
